Khmer Story Lovers

# បញ្ញាមរណៈ

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
« មាតុភូមិ »
ភ្នំពេញ

លេខ ១៥

អ្នកស្រីឃើញកម្លោះញញឹមគាត់អរកើត ស្មានថាកូនប្រុសស្រែកហៅម្ដាយ តែមាណពនុញដាវមកវិញ ! គាត់នៅតែញញឹមបង្អិលដាវទាក់ត្រង់បង្កើះនាយភ្លាម ៗ មាណពយល់ថា ត្រូវគាត់ធ្វើបែបនេះឬ ? នាយវាត់សងមួយស្នៀតដែលយល់ថាត្រឹមត្រូវ ៗ វុនយូសែនពិបាកចិត្ត កាលបើឃើញកូនមិនស្គាល់ជំនាញ, មិនរហ័សរហួន ហើយនឹកថាគ្រូមក្ខុំទឹកកកខ្លាំងណាស់ ឥតបង្ហាត់បង្រៀនកូនគាត់ឲ្យភ្លិនសោះ ៗ អ្នកស្រីដកដាវពីបង្កើះមកទាក់ត្រង់ស្មាម្ដង ហើយធ្វើចាំឲ្យមាណពរកស្នៀតទប់ទល់ បើនាយរកមិនឃើញភ្លាម ៗ គាត់សុខចិត្តធ្វើចាំដោយអត់ធ្មត់ជាទីបំផុត ៗ

ការប្រកួតរវាងវុនយូនិងស៊ុផាន មានសភាពដូចគ្រូនិងសិស្ស នៅពេលហាត់ហ្វឹកហ្វឺនយុទ្ធសិល្បៈទៅវិញ ហើយគ្រូនិងសិស្សនោះជាម្ដាយ–កូនថែមទៀត ៗ ប្រហែលដប់ស្នៀតក្រោយមកអ្នកកម្លោះដូចជាជឿទុកចិត្តខ្លួនជាងមុន លើកដៃលើកជើងរហ័សបន្តិច ធ្វើឲ្យវុនយូសប្បាយចិត្តណាស់ ទំរែម្រួតម្រង់តទៅទៀត ៗ កាលណាមាណពសងត្រូវតាមច្បាប់ម្ដងៗ គាត់ងក់ក្បាលញញឹមសរសើរត្រង់ៗតែម្ដង ៗ នៅខាងណោះស៊ុឈើងនិងប៉ាយវាន់ជាន់ប្រយុទ្ធជាលើកទីបី ឥតហ៊ានធ្វេសប្រហែសឡើយ

ព្រោះម្នាក់ៗស្គាល់ស្នៀតគុនដៃគូអស់ស្រាប់ ។

គេផ្ចង់ផ្ចិតអារម្មណ៍ទៅលើយុទ្ធសិល្បៈ មិនបានយកចិត្តទុកដាក់ដល់ហេតុការណ៍នៅជុំវិញខ្លួ ទោះវុនយូនិងស៊ុផផានប្រយុទ្ធគ្នាបែបណាក៏មិនឃើញផង ។ ប្រសិនបើចង់មើលឬចង់ជួយ ទាល់តែអ្នកនោះសុខចិត្តចាញ់ ព្រោះគេប្រយុទ្ធគួរផ្តាច់ណាស់ ភ្លាត់ស្នៀតបន្តិចត្រូវមានម្នាក់របួ ស្លាប់ ។ ចំណែកអ្នកស្រីវិញ, គាត់អាចមើលប្តីបានតាមត្រូវការ, អាចស្តាប់ដង្ហើម ឈើងទៀតផង ។ គាត់យល់ថាបើស្វាមីជួបគូប្រយុទ្ធមានសមត្ថភាពប្រហាក់ប្រហែលគ្នាបែប គួរបណ្តោយឲ្យប្តីសាកល្បងអស់ចិត្តចុះ គាត់ហ៊ានធានាថាទោះមិនឈ្នះក៏មិនងាយចាញ់ដែរ

អ្នកស្រីសាកល្បងជាមួយមាណពតាំងពីស្នៀតដាវទីមួយរហូតស្នៀតទីចិតសិបពីរ មួយ ហើយគាត់ចាប់ផ្តើមម្តងទៀត ចង់ឲ្យកូនចេះស្ទាត់ ។ មាណពមានកម្លាំងកាយស្គុកស្គ ហើយប្រាជ្ញាឈ្លាសវៃផង, ការសំដែងយុទ្ធសិល្បៈលើកទីពីរ ហុចលទ្ធផលល្អលើសមុនប្រ ដោយនាយចេះវាយលុកផងចេះការពារផង, គួរឲ្យសរសើរ ។ លុះសំដែងពីរចប់ហើយ វុនយូងាកទៅឃើញប្តីប្រយុទ្ធទល់នឹងប៉ាយវ៉ាន់ផានដែល ក៏យល់ថា ល្មមចូលជួយស្វាមីហើ ព្រោះគាត់មិនចង់បង្អែបង្អង់យូរនាំខាតពេល ។

អ្នកស្រីគិតថានាំកូនទៅផ្ទះក្នុងពេលឆាប់ៗនេះ ។ ប៉ុន្តែពេលទេស៊ុផផានយារដាវចាក់ទៀត អ្នកស្រីលើកអាវុធរងគាត់ភ្លាមព្រមទាំងនឹកថា ស្នៀតនេះកូនប្រុសសំដែងបានត្រឹមត្រូវណាស់មិនបា ពន្យល់ថែមទេ ។ ស្រាប់តែភ្លើងទៀនរលត់ឈឹងវុនយូហក់ថយក្រោយភ្លាមឈប់ប្រយុទ្ធ ចំណែកមាណពត្រឡប់ជាខិតចូលប្រាថ្នាសំណេះសំណាល នឹងថ្លែងអំណរគុណចំពោះអ្នកស្រីវ វិញ ។ ដោយហេតុនាយខ្វះការពិសោធន៍នេះឯង បានជាដើរទៅប៉ះចុងដាវវុនយូតែម្តង វុនយូភ្ញាក់ព្រើតដកដៃហក់ថយក្រោយថែមទៀត រួចលូកដៃចាប់ឧបមាណពក្នុងទីងងឹត ព្រមទាំ ស្រែកសួរ :

- កូនប្រុសរបួសហើយឬ? ត្រង់ណា ?

ស៊ុផផានពោលបានតែមួយម៉ាត់ថា ខ្ញុំ..ខ្ញុំ..រួចនាយក្អកខេះៗ និយាយលែងរួច ។ វុនយូ ម្នីម្នាលូកដៃកភ្លើងមកកេះបំភ្លឺបន្ទប់ ឃើញដើមទ្រូងមាណពប្រឡាក់ឈាមប្រឡាក ។ គ្រាន់តែ ឃើញលោហិតក្រហមប្រាលប្រឡាក់អាវ, វុនយូភ័យស្លាដូចមាតាតាំងពីតូចមិនដែលឃើញ ស្រែ

ហៅស្វាមី :

- បងឈីង...ជួយមើលកូនផង !

ស៊ីឈីងនិងប៉ាយវ៉ាន់ជានកំពុងប្រយុទ្ធគ្នាទាំងងងឹត ។ លុះឃើញវ៉ុនយូកេះដែកភ្លើងបំភ្លឺវិញ ហើយឮសម្រែកភិតភ័យទៀត ស៊ីឈីងងាកភ្នែកបែកអារម្មណ៍ដោយឃើញម្ដាយឱបកូនមុខស្លាំង ។ នេះជាចំណុចខ្សោយតែមួយគត់ដែលប៉ាយវ៉ាន់ជានរង់ចាំយូរមកហើយ ។ គាត់រុញចុងដាវចុចជីពចរសំខាន់របស់ស៊ីឈីងភ្លាម ។

## វគ្គទី ១៥

## ក្លួចក្លួនទូកមួយ

ស៊ីឈីងគេចការគាត់រង់អត់ទាន់ឡើយ, តែប៉ាយវ៉ាន់ជានប្រញាប់ដកដៃចេញលោតថយក្រោយយ៉ាងប្រញាប់ ។ ស៊ីឈីងយល់ភ្លាមថា ប៉ាយវ៉ាន់ជានចង់លើកលែងគាត់ម្តងសងអ្នកស្រីវ៉ុនយូដែលលើកលែងគាត់ម្តងដែរ ។ ពេលនេះអត់មាននរណាជំពាក់គុណនរណាឡើយ, ស៊ីឈីងក៏បារម្ភចំពោះរបួសកូនប្រុសក៏ប្រញាប់ស្ទុះទៅពិនិត្យភ្លាម របួសស្រាលទេ, ឈាមនៅហូររមៃៗ ព្រោះវ៉ុនយូដៃស្រាល គ្រាន់តែដឹងថា ប៉ះត្រូវកូនភ្លាមគាត់ដកដាវចេញភ្លាម ។

ពេលដែលអ្នកទាំងពីរភ្លេចខ្លួន មានដាវមួយជ្រែកខ្យល់មកផ្ចាប់បំពង់កមាណពយ៉ាងរហ័ស ។ អ្នកទាំងពីរភ្ញាក់ព្រើត ងើបមើលមុខប៉ាយជានៗ សិស្សភ្នំទឹកកកបន្ទរថា:

- កូនប្រុសលោកប្រមាថកូនស្រីបណ្ដាលចិត្តខ្ញុំ ទាល់តែវ៉ាសម្លាប់ខ្លួនអស់សារបង់ទាំងក្មេងល្ងង់, ខ្ញុំមិននៅស្ងៀមទេ, ត្រូវសងសឹកជាដាច់ខាត ! បើលោកប្រុសលោកស្រីអនុញ្ញាតឲ្យខ្ញុំនាំវ៉ាទៅភ្នំទឹកកកដោយស្រួលវ៉ាអាចរស់បានពីរបីខែទៀត , បើលោកមិនព្រមខ្ញុំកាត់វ៉ាសម្លាប់ភ្លាម !

ស៊ីឈីងនិងវ៉ុនយូងាកមើលមុខគ្នា, វ៉ុនយូព្រឺក្បាលខ្វាកនឹកថាបើគេសម្លាប់កូនមែន, យើងព្រួតដៃគ្នាសម្លាប់គេវិញក៏អត់បានប្រយោជន៍អីដែរ ។ ស៊ីឈីងមិចភ្នែកដាក់ការិយាហើយកាន់ដៃគ្នាលោតទៅក្រៅភ្លាម ។ វ៉ុនយូក្រឡេកឃើញមាណពដែលដួលដេកផ្ងាល់ដីជាចុងក្រោយបង្អស់ដោយទឹកមុខស្រងូតស្រងាត់បំផុត ។ ក្នុងពេលជាមួយគ្នា ដែកភ្លើងក្នុងដៃគាត់រលត់សូន្យឈឹង ។ ប៉ាយវ៉ាន់ជានសម្លុំស្តាប់ស្នូរជើងប្តីប្រពន្ធស៊ីឈីងទៅផុតឆ្ងាយទើបនឹក :

– ពីនាក់នេះផុតទាន់ទៅណាឆ្ងាយទេ ព្រោះគេមិនអស់ចិត្ត ។ មើលទៅដំណើរយើងនៅ
ប្រទះឧបសគ្គច្រើនណាស់ ។

ប៉ាយវ៉ាន់ជាននឹកដល់ឆាកប្រយុទ្ធអម្បាញ់មិញគាត់ព្រឺក្បាលខ្លាក ព្រោះគ្រោះថ្នាក់នៅបន្តិ
សោះ ! ឆាកប្រយុទ្ធបែបនេះគាត់មិនដែលប្រទះមែន ! បើទៀនមិនរលត់អាក្មេងខូចសុីផុងយីត្រូវផុ
ម្តាយវាំនាំទៅបាត់ស្រេច ។ សំណាងល្អដែរ, បើគេដណ្តើមអ្នកទោសមួយរូបនេះបា
ទៀត គាត់មិនអាចរស់នៅលើផែនដីតទៅទៀតបានទេ, រីកិត្តិយសក្រុមភ្នំទឹកកកក៏សាបរលា
តាមហ្នឹងដែរ ។

ប៉ាយវ៉ាន់ជានសម្ងំតមួយសន្ទុះទើបរាវរកដែកភ្លើងកេះទៀនឡើងវិញ ។ លូកក្នុងហោ
ផតប៉ះអ្វីសោះ ទើបគាត់នឹកឃើញអីវ៉ាន់តាំងប៉ុន្មានក្នុងហោប៉ៅអាវនោះ គាត់បានប្រគល់ឲ្យហ៊ូវ៉ាន់យា
ទុកអស់ហើយដើម្បីកុំឲ្យទើសទែងដល់ការប្រយុទ្ធយកឈ្នះបាញ់ ។ គាត់ទទួលយកដែកភ្លើង
ប្អូនប្រុសគ្រូម្នាក់គួសភ្លើងបំភ្លឺកេទៀន ស្រាប់តែភ្ញាក់ព្រញើង ព្រោះសុីផងានទៅទីនេះអម្បាញ់មិញ
ណាបាត់ស្រេច ។ គាត់ព្រឺក្បាលខ្លាក១នឹកថា មានខ្មោចហើយដឹង? បើមិនមែនខ្មោចម្តេច
ផុងយីបាត់ហ៊ើសម្ល៉េះ ?

ប៉ាយវ៉ាន់ជានខឹងណាស់គ្រវែងដែកភ្លើងពោលស្ទុះទៅក្រៅវិញ ។

ខាងក្រៅមានតែពន្លឺព្រះចន្ទនិងហ្វាងគាភឥតឃើញស្រមោលមនុស្សមួយឡើយ , បង្រិតស្រែ
ប្រែប ១ ក្នុងគុម្ពស្មៅ ... អស់ពីនឹកដល់ខ្មោចគាត់ព្រឺក្បាលសំពោងនឹកថា មានអ្នកក្លាហានស
ក្បែរ១ នេះ មើលឆាកប្រយុទ្ធអម្បាញ់មិញ, ដល់ឃើញឱកាសល្អគេជួយរំដោះសុីផងានរត់បាត់ទៅ

ពេលនេះគាត់ណេកឡើងដំបូលប្រោកអើតមើលជុំទិស ឃើញកូនគុម្ពោតព្រៃមួយស៊ុបទ្រុបផ្ទុកអា
លិបលុបពួនបាន ក៏ស្ទុះចុះមកវិញរត់តម្រង់គុម្ពោតនោះស្រែកៈ

– កុំលាក់មុខដូចពង្រួលមិនសមជាអ្នកក្លាហានទេ, សុំចេញមកសាកល្បងគ្នាមើលសិន

គាត់រង់ចាំបន្តិចមិនឮនរណាឆ្លើយតប ក៏ស្ទុះវាត្រឡប់ចូលកេងពាសវិញឥតឃើញនរណាដដែ
មានតែខ្យល់ត្រជាក់បក់ជ្រុះស្លឹកឈើខ្សាក ១ ...

ប៉ាយវ៉ាន់ជានបាត់ខឹងនឹកត្រេកអរម៉្យាងដោយបានសាកល្បងស្នាដៃអ្នកគុនមិយមល្បីល្បាញដូចគ្នា
គាត់ព្រឺក្បាលបិនទេះបប់នឹកថា ភ្នំខ្ពស់តែងមានដើមឈើដុះខ្ពស់លើសភ្នំ ។ ប៉ុន្តែភ្នាមទេ

គាត់ស្រមៃឃើញមុខកូនស្រីខ្លួនល្អក់ តំសោកវិយោគក្រាម, ដកដង្ហើមធំគួបគ្នើនដុតទៀនបំភ្លឺដើម្បី ស្រាយដីពចរឲ្យប្អូនរួមគ្រភ ។

ខណៈនោះប៉ាយរ៉ាន់ជានស្រឡាំងកាំងម្ដងទៀត ដោយឃើញស្នាមម្រាមដៃប្រាំច្បាស់ក្រឡែត លើថ្ពាល់ប្អូន ១ គ្រប់គ្នា , ជាពិសេសស្នាមនេះមានសម្បុរខ្មៅជាំផតចូលក្នុងសាច់ ។ គាត់ លើកដៃជូតថ្ងាសសួរស្ងួន :

- អ្នកណាវាយ? វាយពីកាលណា?

ស្នាមខ្មៅនេះគួបសមជាដៃមនុស្សស្រី តែប៉ាយរ៉ាន់ជានធ្ងល់មិនឈប់ ព្រោះបើប៉ះលើវិជ្ជាដៃខ្មៅ ឬវិជ្ជាដៃដែក ប្អូនគាត់តាំងអស់ស្លាប់បាត់បង់ជីវិតទៅហើយ , ម៉េចគេនៅរស់? ហ៊ីរ៉ាន់យាន តបមុនគេ :

- ខ្ញុំឥតដឹងនរណាវាយទេ ។

មិនរ៉ាន់ហ្វូស្រែកប្រទេច :

-អាចោរ , អាក្ត , លួចវាយគ្នាក់គេដូចឆ្កា, មិនមែនអ្នកក្លាហានទេ . . .

ស្រែកទៅស្រែកមកឥតហាននរណាដឹងរឿសោះ ក្រៅពីគេទះកំផ្លៀងម្នាក់មួយដៃ នៅពេលដែលប៉ាយរ៉ាន់ជានរត់ទៅក្រៅ ។ ម្នាក់ ១ ឈឺណាស់តែមិនព្រួសម្ដេចទះឡើយ, កាលបើទទួលមួយដៃហើយគេឥតដឹងសត្រូវទៅទះនរណាទៀតទេ ពាល់តែបងរួមគ្រភជុំទៀនភ្លឺវិញ ទើបឃើញស្នាមដៃខ្មៅព្រីកលើថ្ពាល់គ្រប់គ្នា ។ ប៉ាយរ៉ាន់ជានឈរធ្ងើងស្ញើងគិត:

- អ្នកដែលមករំដោះស៊ុផានពិតជាអ្នកទះកំផ្លៀងប្អូនៗ យើងហើយ ។ គិតទៅវាហ៊ានណាស់ហ្ន! វាចាប់អ្នកទោសយើងហើយ វាហ៊ានសម្លុតប្អូនក្នុងនេះសិនរើចាំងលុះយើងរត់ទៅក្រៅទើបទះកំផ្លៀងប្អូនអស់នេះហើយនាំស៊ុផានចេញទៅបាត់ ។ ជននេះប្រើកម្លាំងសម្ងាត់ទះត្រូវសាច់មិនឲ្យព្រួសម្ដេចឃើញថាខ្លាំងពូកែជាងយើងហើយធ្លាតវាងវៃណាស់ ។

ស៊ុផានកាលប៉ះចុងដាវអ្នកស្រីវ៉ុនយូនោះនាយមានរបួសស្រាល ហើយគ្នានឈឺចាប់ផង ។ លុះស៊ុឈើងទិនវ៉ុនយូចេញទៅឆ្ងាយបាត់អស់ នាយម៉េរបញ្ចីលង ឃើញស្រាប់តែមានដៃមួយទន់ល្អក់ល្អកមកខ្ទប់មាត់នាយហើយដៃម្ខាងទៀតអូសនាយថ្នមៗទៅពួនក្រោមគុ ។ មួយសន្ទុះទៀតនាយត្រូវគេស្ពាយរត់ចេញទៅលឿនរ៉េវ ។ មួយស្របក់គេលោតចុះទូកមួយមានមនុស្សដុតចង្កៀងចាំ ។

នាយបើកភ្នែកខ្វាក់ឃើញចិនគុនកាន់បង្កៀនគោមអគ្គិយក្បែរខ្លួន ។ មាណពត្រេកអរណាស់ស្រែក

- ចិន ៗ គុន ៗ ... នាំពខ្ញុំមកឬ ?

ចិនគុនបួញមាត់បន្ទោស :

-បងឯងក៏ភ្លើមែនហ្ន៎ ! គ្រាន់តែអ្នកណាជួយក៏ចាយមិនត្រូវដែរ ។ គឺលោកតាស្តាយម

ណាំ !

មាណពងាកទៅឃើញចិនមិនហួសប៊ីអគ្គិចបជន្លង់នៅក្បាលខ្នុក សំឡឹងមេឃសំឡឹងផ្កាយ

ព្រងើយ ហាក់មិនរវល់នឹងបៅស្រីសោះ ។ មាណពពោលភ្លាម :

- លោកតា ... យកខ្ញុំមកធ្វើអី ?

ចិនមិនហួសប៊ីគ្រហឹម :

-ហ៊ឹះ! អាគុន ! អាប្រមក់នេះឆ្កួតលីលាទេតើ ! ឯងរៀបការជាមួយវាធ្វើអី ? មិនទាន់បា

ផ្សំដំណេកផងដែលល្មមសម្លាប់វាចោលទៅ ។

ចិនគុនស្រែកដំពាស់ :

- ទេ ! ទេ ! បងបានមានជម្ងឺធ្ងន់ពេកក្ដេចរឿងល្អអាក្រក់ណាំលោកតា ! យូរទៅគា

ស្រួលបួលវិញហើយ ។ មក៏បងបាន ខ្ញុំរុំបួសឲ្យ ។

នាងដោះអាវមាណព ហើយយកកូនកន្សែងជ្រលក់ទឹកលាងជូតឈាមស្អាត ទើបយកថ្នាំម

លាប ។ បន្ទាប់មកនាងហែកដៃអាវនាងផ្សាល់រុំរបួសយ៉ាងផ្ចិតផ្ចង់ ។ មាណពត្រេក

ណាស់ពោល :

- សូមអរគុណនាងណាស់ ៗ អើហ្ន៎ ! ចិន១ គុន១ និងលោកតាពួនក្រោមគុកធ្វើអី ដូចគេលេ

បិទពួន ? យី ! សប្បាយណាស់ ...

ចិនគុនស្រែកតំហាក :

- យី, នៅសប្បាយទៀត ! ពេលដែលឪពុកម្ដាយបងឯងប្រយុទ្ធជាមួយវាទ៍ជាននោះខ្ញុំភ័យស្ទើ

បង់ផាប់ហើយ ។

មាណពសួរដោយឆ្ងល់ :

- ឪពុកម្ដាយខ្ញុំ ? អូ, នាងថាបុរសម្នាក់ស្លៀកពាក់ខ្មៅជាឪពុកខ្ញុំឬ ? ស្រីម្នាក់ស្អាតបាត

ម្តាយខ្ញុំផង ? ម៉ែខ្ញុំមិនមែនអ៊ីចឹងទេ, មិនស្អាតដូចគាត់ទេ !

ចិនតុងដកដង្ហើមធំ :

- បងបានអើយ ! បងឈឺម្តងនេះធ្ងន់ធ្ងរណាស់, ក្មេងឪពុកម្តាយអស់រលីង ! ចំណែកគុនដាវពាំងចិតសិបពីរស្នៀតៈនោះក៏មិនល្អមើលដែរ, ប្រហែលបងក្មេងយុទ្ធសិល្បៈអស់ដែរ ? ហ៊ឺ ! ដូចជាមិនសមសោះ !

ត្បិតចិនមិនហួសប៊ីនាំទៅស្រីឃ្លាំមើលប៉ាយវ៉ាន់ផាន ស្ពាយស៊ីផានរត់តាំងពីទីតាំងក្រុមឈានល្អមក ។ គាត់លបមើលស៊ីឈីង និង សិស្សក្តីទឹកកកប្រយុទ្ធគ្នាតាំងពីដើមដល់ចប់ទៀត ។ លុះមានឱកាសល្អ គាត់ជួយស៊ីផានរត់ពួនក្រោមតុ រង់ចាំប៉ាយវ៉ាន់ផានរត់ទៅក្រៅកសត្រូវ ទើបស្ពាយនាយរត់តាមក្រោយ , ទុកឲ្យចិនតុងសង្កែងយុទ្ធសិល្បៈប្រចាំគ្រួសារខេះកំផ្លៀងសិស្សក្តីទឹកកកម្នាក់មួយរេ តាមក្រោយ ទៅជួបគ្នាក្នុងទូក ព្រោះនាងខ្លាចញញើតប៉ាយវ៉ាន់ផានដែរ ។

ពេលនេះស៊ីផានពោលតំរង្ងល់:

- ខ្ញុំគ្មានយុទ្ធសិល្បៈអីទេ ។ សំដីអ្នកនាងខ្ញុំមិនយល់មួយម៉ាត់សោះ ។

ចិនមិនហួសប៊ីស្ទុះក្ងួតគំហកដាក់ទៅស្រី:

- អាតុង ! ទៅឯងត្រូវស្នេហ៍អាប្រមត់ហ្នឹងឬ បានជានៅនិយាយកេអាមនុស្សចំកួតល្ងីល្ងើបែបនេះ ? គាបង់តែនឹងវាសម្លាប់ឥឡូវហ្នឹង ! ទៅឯងកុំភ័យ ចាំគារើសរកយុវជនស្រស់សង្ហាមួយរូបធ្លាតវ៉ងវៃ ហើយបេះថ្នាក់ថ្មការ្ងរលោមមកធ្វើទៅប្រសា ។

ចិនតុងស្រក់ទឹកភ្នែកតបទាំងអណ្តឺតអណ្តក់ :

-ខ្ញុំ ... ខ្ញុំមិនចង់បានយុវជនណាក្រៅពីគាត់ទេ ! គាត់ ... គាត់មិនមែនឆ្កួតលីលាទេគា ! មកពីគាត់ឈឺខ្លាំងក្តៅខ្លួនវង្វេងស្មារតីណាលោកតា!

ចិនមិនហួសប៊ីគំហកទៀត :

- យើអើ ! វង្វេងខួរក្បាលខួរស្អី? មើលតែវ៉ាយញញ្ញាស្នៀតដាវក្នុងកេនកញ្ញាស់នោះ ទៅឯងឃើញស្រាប់ហើយ ! ច្រឹក ១ ភ្លើ ១ ធ្វើឲ្យតាប្រេះទ្រូងស្ទើរស្លាប់នឹងកន្លែង ។ ហ៊ុះ ! ធ្វើដូចជាមនុស្សហាត់រៀនថ្មីថ្មោងអ៊ីចឹង, ចេញមកមួយស្នៀតមានកំហុសរាប់មិនអស់ ។ ហ៊ឹះ ! ល្ងើទៅទៀតត្រង់គេដកដាវចេញហើយ វ៉ស្ទុះចូលស្ទើរគេសេចក្តីស្លាប់ ទាល់តែឃ្មួស

ប៉ុណ្ណឹងទើបវាអស់ចិត្ត  មនុស្សក្រីក្រៀមបែបនេះរស់មិនបានយូរទេ, ! គង់ដល់ថ្ងៃគេសម្លាប់វាពោល
គ្នាតមិនខាន ។ ចៅស្រីគិតមើល ? បើលេចឮដំណឹងពេញពិភពគុកថា  ចៅប្រុសាទីងមិនហួស
ត្រូវគេសម្លាប់, រូបតាអាចរស់លើផែនដីតទៅទៀតដែរ ? មិនកើតទេចៅ, សម្លាប់ភ្លាមទៅ, ប្រ
តែសម្លាប់ជាដាច់ខាត!

ទីងគុងស្តាប់ផងខាំបបូរមាត់ទប់ចិត្តផង ។  នាងស្គាល់ជីតាច្បាស់ណាស់ , តែនិយា
យ៉ាងម៉េចគាត់ធ្វើយ៉ាងហ្នឹងហើយប្រកែកមិនបានទេ, បានត្រឹមពេយមាត់ឥតប្រយោជន៍ ។

នាងសួរបន្ទប់ :

-លោកតា , ខ្ញុំត្រូវធ្វើយ៉ាងម៉េចទើបលោកតាលែងសម្លាប់គាត់?

- . . ហាស ! រឿងអីបានជាលែងសម្លាប់វា ? ត្រូវសម្លាប់វាពោលដាច់ខាត !
មិនដូច្នោះទេតាអាម៉ាស់មុខណាស់ ។ បើអ្នកគុកនិយមឮថាទីងមិនហួសបីសម្លាប់ចៅប្រុសា នេ
ធ្វល់ឡើយ , អាណិតកុំឲ្យគេនិយាយពីមួយទៅមួយថា ចៅប្រុសាទីងមិនហួសបីត្រូវគេសម្លាប់
ណា៎ ! ឯងឲ្យតាធ្វើម៉េចទៅហ្នះ ?

- ធ្វើម៉េច ? លោកតាត្រូវសម្លាប់សត្រូវដែលហ៊ានសម្លាប់គាត់ណា៎ !

ទីងមិនហួសបីសើចខ្ទឹរ :

- សងសឹកឲ្យអាមនុស្សល្ងីល្ងើនេះឬ ? ចៅឯងទុករូបតាជាមនុស្សជំពូកណាដែរ ?

ទីងគុងទ្រហោយំ :

- លោកតាប្រើខ្ញុំឲ្យសំពះផ្ទឹមទទួលគាត់ជាប្តី, ឥឡូវលោកតាបង់សម្លាប់គាត់ . . . ! ហ៊ឺ ! ប
ខ្ញុំក្លាយជាស្រីមេម៉ាយហើយ ! ហ៊ឺ . . ហ៊ឺ . . .

ទីងមិនហួសបីអេះក្បាលរួចតប:

- កាលណោះតាសាកល្បងទីងវាឃើញវាមានកម្លាំងល្មមធ្វើចៅប្រុសាបានណា៎ ! តាមានដាំង
ជាវាឆ្កួតលីលាអីចឹងឯណា ? ណ្ហើយបើមិនព្រមឲ្យតាសម្លាប់វាត្រូវបំពេញលក្ខខណ្ឌមួយចុះ ។

ទីងគុងឮថាមានសង្ឃឹម ក៏សួរវិញយ៉ាងរីករាយ :

- លក្ខខណ្ឌអីទៅ ? លោកតាឆាប់ប្រាប់មកចុះ !

- តាថាវានេះជាមនុស្សឆ្កួតលីលា , ត្រូវតែសម្លាប់ចោល! តែចៅឯងថាវាមិនមែនឆ្កួតលី

ទេ, មិនត្រូវសម្លាប់ចោលទេ ! ណ្ហើយចុះតាទុកពេលឲ្យវាជប់ថ្ងៃ ! ក្នុងវង់ជប់ថ្ងៃវាត្រូវទៅប្រយុទ្ធនឹងប៉ាយវ៉ាន់ផានជាដាច់ខាត ។ បើភាចវាយប៉ាយវ៉ាន់ផានស្អីគេនោះស្លាប់, បើសម្តឲ្យចាញ់ចុកស្បាត តានឹងលើកលែងទោសឲ្យវាភ្លាម ហើយព្រមទទួលស្គាល់ជាចៅប្រុសាពេញលក្ខណៈផង !

ទីងគុងជកផ្អើមធំទឹកថា: « ប៉ាយវ៉ាន់ផានមានវិជ្ជាគុនដាវខ្លង់ខ្លស់ណាស់តាទៅឃើញបាន ឃើញផ្ទាល់ភ្នែកហើយ ! ពេលនេះបងជាងទើបនឹងរើបពីឈឺ ហើយមានរបួសថ្មី ៗ ទៀតធ្វើម៉េចក្នុងរយៈជប់ថ្ងៃគាត់អាចនឹងប្រយុទ្ធឈ្នះ អ្នកក្លាហានដ៏ល្បីនេះបាន ? » នាងតប:

- លោកតា ! លក្ខខណ្ឌនេះពិបាកនឹងសម្រេចណាស់ !

-ពិបាកក៏ដោយ ! ស្រួលក៏ដោយ ! បើវាវាយមិនឈ្នះប៉ាយវ៉ាន់ផានទេ តានឹងសម្លាប់អាចំកួតនេះចោលភ្លាម !

ទីងតុងសែនព្រួយបារម្ភ, នាងបែរមើលមាណពឃើញនាយដេកធ្វើហី ក៏សួរតិចៗ:

- បងជាន ! លោកតាថាឲ្យបងទៅវាយកំចាត់ប៉ាយវ៉ាន់ផានឲ្យបានក្នុងវង់ជប់ថ្ងៃ ! បងយល់យ៉ាងម៉េច ?

ស៊ីផជានតបធ្វើព្រងើយ :

- ប៉ាយវ៉ាន់ផាន ? គាត់ពូកែណាស់គ្មានអ្នកណាវាយឈ្នះគាត់ទេ ! តើខ្ញុំធ្វើម៉េចនឹងវាយឈ្នះគាត់ !

- ចាស មែនហើយ ! តែលោកតាប្រាប់ថាបើបងវាយមិនឈ្នះគេទេ គាត់ត្រូវតែសម្លាប់បងចោល !

ស៊ីផជានសើចញឹមៗតប :

-នៅស្រួល ៗ សោះហេតុអ្វីក៏ចង់សម្លាប់មនុស្សទៀតហើយ ? លោកតានិយាយលេងទេម៉េចនាងក៏យកម៉្លេះ ? លោកតាជាមនុស្សល្អមិនមែនមនុស្សអាក្រក់ទេ ម៉េច . . .ម៉េចគាត់ចង់សម្លាប់ខ្ញុំទៅវិញ ?

ទីងតុងជកផ្អើមធំ នឹកក្នុងចិត្ត: «បងជានពិតជាល្ងីល្ងើបន្តិចមែនតែដឹងខុសត្រូវអីសោះ ឥឡូវមានតែទទួលយល់ព្រមតាមលោកតាទៅចុះ ដើម្បីឆ្លៀតពេលជប់ថ្ងៃនេះរកមធ្យោបាយឲ្យគាត់រត់គេចចេញ» ។ ម៉្លោះហើយនាងពោលទៅកាន់ទីងមិនហ្គួសថា :

– បាទ ! លោកតាខ្ញុំយល់ព្រមហើយ ក្នុងវេលាដប់ថ្ងៃនេះខ្ញុំនឹងគិតគូរឲ្យគាត់ទៅវាយប្រហ
ប៉ាយវ៉ាន់ជានឲ្យទាល់តែបាន !

ទីងមិនហួសបីគ្រហឹមហ៊ឹះ តប :

–តាឃ្លានណាស់, ឆាប់ទៅដាំបាយមកស៊ី ! តានិយាយប្រាប់ឯងឲ្យហើយថាទីមួយមិនបង្
បង្រៀនទីពីរកុំរត់ ទីបីមិនលើកលែងទោស ។ មិនបង្ហាត់បង្រៀនគឺមិនបង្ហាត់យុទ្ធសិល្បៈ
ក្លួតនេះទេ កុំរត់គឺហៅកុំមានបំណងបណ្ដាះវាឲ្យសោះ , តែតាដឹងថាវាចង់រត់ភ្លាមតាច្បាស់ជាស
ពេលមួយរំពេចមិនចាំដល់ដប់ថ្ងៃទេ ។ ឯថាមិនលើកលែងទោសនោះមិនបាច់និយាយច្រើ
ទៅក៏យល់ដែរ

ទីងគុងតប :

–បើលោកតាចាត់ទុកគាត់ជាមនុស្សត្រួតលីលាហើយ ទោះបង្ហាត់បង្រៀនយុទ្ធសិល្បៈក៏មិនចេះ
ហេតុអ្វីចាំបាច់មានពាក្យថាមិនបង្ហាត់ ?

ទីងមិនហួសបីសើចញឹមៗ :

– កលល្បិចបញ្ឆោតចិត្តរបស់ចៅគ្មានប្រយោជន៍ទេ ម្យ៉ាងទៀតបើតាព្រមបង្ហាត់បង្រៀន តើ
រយៈដប់ថ្ងៃវាអាចមានសមត្ថភាពគ្រប់គ្រាន់នឹងវាយប្រហារប៉ាយវ៉ាន់ជានបានមែនឬ ? ណ្ហើយ
បង្ហាត់ដប់ឆ្នាំក៏អត់អំពើដែរ ។

ទីងគុងផុសបានគំនិតមួយក៏ពោលឡើង :

– ល្អ ! បើលោកតាមិនបង្រៀនទុកឲ្យខ្ញុំបង្ហាត់វិញ ។ លោកតា ! ខ្ញុំមិនដាំបាយ
ត្រូវតែខំតទ្យល់ណែនាំស្លៃតទូះឲ្យបង៍ណាន !

ពេលនេះទូកកំពុងផត់ខ្យល់អណ្ដែតទៅទិសខាងកើតតាមបណ្ដោយទឹក ។ មេឃកាន់
ច្បាស់ឡើងហើយ ដោយមានពពុះអព្ទាសពេញផ្ទៃទន្លេ ។ ទីងមិនហួសបីគំហកទាំងកំហឹង

– បើចៅមិនទៅដាំបាយ ចង់ធ្វើឲ្យតាឃ្លានស្លាប់ឬ ?

– បើតាចង់សម្លាប់ប្ដីខ្ញុំ ខ្ញុំត្រូវតែបង្អត់តាឲ្យស្លាប់មុន !

– ហ៊ឹះ ! ហ៊ឹះ ! ឆាប់ទៅដាំបាយភ្លាម !

ទីងគុងមិនរវល់នឹងគាត់ទេ នាងបែរទៅប្រាប់ស៊ីជាន :

- បងធាន ! ខ្ញុំបង្ហាត់យុទ្ធសិល្បៈបង ធានាថាក្នុងរយៈពេលបីថ្ងៃបងអាចវាយផ្តួលបាយតានជាមិនខាន !

ចិនមិនហួសបីធ្វើហ៊ឹះ ! ពោលថា:

- និយាយផ្តាស ! គាធ្វើមិនបានផង បើប្រមុកឯងអាចធ្វើកើតឬ ?

ជីតាមិងទៅបេះផ្លែកន្ទាទៅវិញទៅមកមិនបេះអស់មិនបេះហើយ ។ តាមពិតក្នុងចិត្តចិនគុងក្តុកក្តួលជ្រួល ប្រឹបល់ខ្វល់ខ្វាយណាស់ពុំដឹងគិតរកមធ្យោបាយបែបណា ដើម្បីអង្វរកុំឲ្យលោកតាសម្លាប់ស៊ីផធាន ។ នាងធ្លាប់ស្គាល់ចិត្តលោកតា ប្រសិនបើអង្វរគាត់តាមស្រួលនោះឥតប្រយោជន៍ទេ ម្ល៉ោះហើយបេះតែរកមធ្យោបាយដើម្បីដំតាស់ ក្រែងលោអាចធ្វើឲ្យគាត់ប្រែចិត្តគំនិត ។ នាងនឹកថា:

-បើយើងមិនដាំបាយដល់គាត់ឃ្លានច្បាស់ជាឲ្យខូកអែបប្រាំង ឡើងគោកចិញ្ចឹមមួយចំណីយ៉ាងប្រាជក ហើយពេលនោះនឹងមានឱកាសបណ្តោះបងធានបានមិនខាន ។

ស៊ីផធានឃើញចិនមិនហួសបីឃ្លានឡើងមុខជូរ ឯខ្លួនឯងនឹកហៅវែវ ហើយលោយមិនយល់ចិត្ត ចិនគុងកំព្រោកឡើងពោលថា :

-ចុះខ្ញុំទៅដាំបាយវិញ !

ចិនគុងគំហកទាំងកំហឹង :

-បងទើបនឹងមានរបួស ហើយចំធ្វើការទៀតប្រយ័ត្នមុខរបួសហើមតិតយ៉ាងដូចម្តេចទៅ?

ចិនមិនហួសបីគំហកភ្លាម :

- ថ្នាំរបស់ត្រកូលចិនសក្តិសិទ្ធិណាស់ គ្រាន់តែលាបភ្លាមជាភ្លាម ។ របួសមិនធ្ងន់ប៉ុន្មានទេ ខ្លាចអី ? ល្ហើយអាទៅអើយឆាប់ដាំបាយឲ្យតាស៊ីភ្លាមទៅ !

ចិនគុងសួរ :

- បើគាត់ដាំបាយឲ្យតាពិសា តើតាលែងសម្លាប់គាត់ឬ ?

- ដាំបាយគឺដាំបាយ សម្លាប់មនុស្សគឺសម្លាប់មនុស្ស ទាំងពីរនេះមិនអាចបញ្ចូលគ្នាបានទេ ។

សំដីនេះបញ្ជាក់ថា គាត់នៅតែចង់សម្លាប់ស៊ីផធានដដែល ។ មាណពយកដៃស្ទាបច្រុង ឃើញថា មិនស្ទូវឈឺមែន ក៏ដើរទៅកន្សែងខ្ទុកជួសអង្ករដាំបាយ ។ ទីនេះតាចាស់ម្នាក់កំពុងកាចចង្កូតយ៉ាងស្ងៀមស្ងាត់ ដោយពុំរវល់នឹងអ្នកទាំងពីរដែលកឡូឡាទេ ។ ការដាំស្លដាវិជ្ជាជំនាញ

របស់ស៊ីផាន ។ មិនយូរប៉ុន្មានទាយកាំងត្រីពីរ និងដាំបាយមួយឆ្នាំងឆ្អិនស្រេច ជុំក្លិនឈ្ងុយឈ្ងប់គួរឲ្យស្រក់ទឹកមាត់ ។ លុះទីឯងមិនហួសបីបរិភោគរួច គាត់អួតសរសើរមិនដាច់ពីមាត់ហើយប្រាប់ថា :

– បើយុទ្ធសិល្បៈឯងបានពាក់កណ្ដាលវិជ្ជាធ្វើម្ហូបនេះពិតជាប្រសើរណាស់ ហើយគាត់មិនសម្លាប់ឯងដែរ ។ ប៉ុន្តែគួរស្ដាយណាស់ៗ ! កាលនោះប្រសិនបើកុំឲ្យឯងសំពះផ្ដើមជាមួយកាគុនហើយឲ្យធ្វើចុងភៅវិញ ប្រហែលគាមិនសម្លាប់ឯងទេ ហើយបើអ្នកដទៃចង់សម្លាប់ឯងក៏គាមិននៅស្ងៀមដែរ ។

ទីងគុងជួសបាយមួយចានធំនិងចាប់ត្រីមួយកំណាត់យកទៅឲ្យតាចាស់ ដែលកំពុងកាចបង្ហិតបរិភោគ ។ ក្រោយពីស្រស់ស្រូបរួចរាល់ហើយ ស៊ីផាន និង ទីងគុងអង្គុយលាងចាននៅកន្ទ្រក ។ ទីងគុងឃើញដីតានៅឯក្បាលទូកក៏ពោលតិចៗថា:

–បន្តិចទៀតខ្ញុំបង្ហាត់ស្នៀត«ចាប់ខ្ញុំ»មួយក្បួនឲ្យបង, បងត្រូវតែចំយកចិត្តទុកដាក់ឲ្យមែនទែនណា!

មាណពតប:

–បើហាត់បេះហើយ ឲ្យខ្ញុំទៅប្រកួតប្រជែងនឹងលោកគ្រូបាយនោះឬ ?

–បងឯងពិតជាមនុស្សភ្លួតលីលាមែនឬ? បងជាន .. កាលពីមុនបងមិនមែនដូច្នេះទេ ។

–ចុះកាលពីមុនខ្ញុំយ៉ាងម៉េចទៅវិញ ?

ទីងគុងមានទឹកមុខក្រហមបន្តិច, ឆ្លើយ:

– កាលពីដើមបងជួបខ្ញុំម្ដងៗ សំដីសំពៅពាក្យពេចន៍ផ្អែមជាងទឹកឃ្មុំទៅទៀត ហើយធ្លាកល្អាសវៃណាស់បេះនិយាយសើចលេងធ្វើឲ្យខ្ញុំសប្បាយរីករាយស្ទើរហើបខ្លួនពីដី ហើយសំដីមួយម៉ាត់ៗដែលបងនិយាយចេញមកប្លែកៗទៀតផង ' ប៉ុន្តែឥឡូវនេះ បង ប្រែអស់ហើយ ។

ស៊ីផានដកដង្ហើមធំតបថា:

– ខ្ញុំប្រាប់ហើយប្រាប់ទៀតថា ខ្ញុំមិនមែនបងជាននាងទេ ។ បងជានបេះធ្វើឲ្យនាងសប្បាយរីករាយ , ខ្ញុំឥតបេះទេសូមនាងចាប់ទៅរកបងជានរបស់នាងចុះ ។

ទីងគុងអង្វរតិចៗ :

– បងជានកុំខឹងនឹងខ្ញុំអី ។

មាណពគ្រវីក្បាល :

- ខ្ញុំមិនដឹងទេ ។ ចេះតែខ្ញុំនិយាយតាមត្រង់ណា ! ម៉េចមាំបិទព្រាបជឿ ?

ច័ន្ទគុន្ធសម្លឹងទឹកទន្លេស្រមៃទៅឆ្ងាយ ពោលរអ៊ូ ១:

- មិនដឹងថ្ងៃណា ឆ្នាំណាទើបគាត់នឹកឃើញរឿងដើមហើយប្រែអាកប្បកិរិយាវិញហ្ន៎ !

នាងក្រមុំស្រមៃពាល់តែគ្មឹកស្មារតី របូតបានពីដៃធ្លាក់ទឹកក្នុង ។ មាណពស្រង្វឹតស្រវាតដៃ ពោលបន្ត :

- ច័ន្ទ ១ គុន្ធ ១ , ខ្ញុំមិនអាចក្លាយជា « បរិជាន „ នាងទេ ព្រោះខ្ញុំមិនមែនឈ្មោះបានណា៎ ! បើខ្ញុំជាមនុស្ស... ក្លួតលើណាមែន , នាងលែងស្រឡាញ់ខ្ញុំហើយអ្ហ៎ះ ?

ច័ន្ទគុន្ធបេញទឹកភ្នែករលីងរលោងស្រក :

- ខ្ញុំមិនដឹងទេ ! ខ្ញុំមិនដឹង !

នាងលើកដៃខ្ទប់ត្រចៀកហើយលើកបានម្ដងម្ហេយត្រង់ពោលគុន្ធទន្លេដើម្បីបន្ទប់ទុក្ខសោយកំហឹង ។

មាណពពោលទៀត:

- នាង . . . ច័ន្ទ ១ បើខ្ញុំចេះនិយាយឲ្យនាងសប្បាយចិត្តខ្ញុំមិនខ្ជិលទេ, ខ្ញុំសុខចិត្តនិយាយពាន់ថ្ងៃពាន់យប់ឲ្យនាងស្ដាប់ហើយ ។ ប៉ុន្តែធ្វើម៉េចបើខ្ញុំមិនមែន „បរិជាន„ ដែលនាងស្រឡាញ់ ? ខ្ញុំមិនចេះធ្វើពើទេ ។

ច័ន្ទគុន្ធងាកខ្វាប់មកសង្កេតមុខអ្នកកម្លោះម្ដងទៀត ។ ពេលនេះព្រះចន្ទរះខ្ពស់លើមេឃាពោល ស្មើលើមុខមាណពច្បាស់ពែស ។ នាងសម្លឹងមុខមាត់ភ្នែកប្រមុះគេឃើញអ្វីថ្លែកសោះក៏ផ្ទុកផ្ដើមថា :

-បើមិនមែនបរិជានទេហេតុអីបងអានស្នាមញ្ញេញខ្ញុំនៅលើស្មា ? បើមិនមែនបរិជានហេតុអ៊ីបងចូលចិត្តនិយាយលេងសើចនឹងនារីគ្រប់រូប, ម៉េចបងទៅសាសង់ជាមួយនាងហ្លួងខាន់ក្នុងទឹកកក ? ហេតុអីបងជាគ្រឡប់ជាល្បីល្បើដូចមនុស្សឆ្កួតជ្រូក ? ម៉េចក៏បាត់សំដីពៅហាឫកពារទិលខូចអស់រលីង ?

មាណពអស់បើគិតសើចខ្ញៅ :

- នាងទទួលខ្ញុំជាប្ដីហើយម៉េចក៏ពោលបែបហ្នឹង ? មិនចង់បានប្ដីមនុស្សល្អត្រឹមត្រូវទេឬ?

ច័ន្ទគុន្ធគ្រវីក្បាល:

-ទេ ១, ខ្ញុំស្រឡាញ់តែបរិជានមួយគត់ សុខចិត្តឲ្យគាត់ទិលខូចខ្ជះខ្ជុះ ។ បងទៅល្អបប្រពន្ធគេ

ក៏បាន, ទៅចាប់ក្បួនក្រមុំគេក៏បានទៀត ។ ខ្ញុំមិនចង់ឲ្យបងធ្វើត្រឹមត្រូវដូចស្រីគ្រប់លក្ខណ៍ទេ

នាងមានមុខស្លុតទឹកចាន់ យាយយូរតែខ្វល់ខ្វាយប្រែង ដោះស្រាយមិនស្រឡះសោះ ភ្លាមនោះនាងចិនចេះធ្លូលលូកដៃចាប់ស្លឹកត្រចៀកនាយមូលក្រេកដាច់ស្បែកចេញឈាមរមែៗ ។មាណ ឈឺពេកទ្រាំមិនបានក៏លើកដៃវង់កាត់ភ្លាម ។ រីឯកុងប៉ះណាគុម្ព្រាងក្តៅគគុកកើតចេញពីដៃមាណ មកខ្លាតថយក្រោយប៉ះដំបូលទូកម៉ាំងវិះធ្លាក់ទឹក ។ នាងស្រែកអួយដេវថា:

- អាខ្វាចយក៍ ! វាយប្រពន្ធផង ? ម៉េចក៏ដៃធ្ងន់ម៉្លេះ ?

ស៊ីផានតប យ៉ាងប្រញាប់ :

- អត់ទោស ... អត់ទោស ! ខ្ញុំឥតចេតនាទេ ។

នារីបមើលដៃឃើញជាំខៀវមួយដុំស្រាប់តែលែងខឹងភ្លាម នាងបញ្ចោញទឹកមុខរីករាយក្តាប់ មាណពយ៉ាងណែនត្រវ៉ចុះឡើងព្រមទាំងពោល :

- បងណាន, បងពិតជាបញ្ឆោតខ្ញុំហើយ; កុំធ្វើពើយូរពេក ។

មាណពស្រឡាំងកាំង:

- ធ្វើពើយ៉ាងម៉េចអ៊ីចេះ ?

- បងមិនទាន់ក្លួចយុទ្ធសិល្បៈអស់ទេ ។

- ខ្ញុំគ្មានយុទ្ធសិល្បៈស្អីទេ !

ចិនតុងគំហក:

- បងឯងនៅតែនិយាយផ្ដេសផ្ដាសអ៊ីចុះ ? ខ្ញុំលែងវល់ហើយ ។

ពោលចប់នាងលើកដៃទះថ្ពាល់នាយមួយដៃ ។ ស៊ីផាន ផ្ងៀងក្បាលគេចរួចលើកដៃ កាត់ ។ ប៉ុន្តែយុទ្ធសិល្បៈប្រហាំត្រូសារចំណីចំរៀក ហើយរហ័សណាស់នាយវង់ខុសចេញថែមទាំង ថ្ពាល់ខ្លាគៗ ។ ចិនតុងស្រែកអួ ! ដោយភ្ញាក់ផ្អើលព្រោះមាណពវង់កាត់ស្នៀតនាងមិនបា នាងឆ្ងល់ណាស់បើស៊ីផានមិនក្លួចយុទ្ធសិល្បៈទេ ម៉េចត្រូវវង់បានជាដាច់ខាត ។

ពេលនេះគ្រូឡេកឃើញថ្ពាល់មាណពលេចស្នាមដៃខ្មៅៗ នាងអៀនខ្មាសណាស់មិនគួរប្រើកម្លាំ សម្លាប់ទះថ្ពាល់ស៊ីផានសោះ ។ ស្ងប្បាញ់មិញមាណពវង់កាត់ខុសទំនងដូចមនុស្សឥតចេះ វិជ្ជាមែនៗ ។ នាងស្ដាយក្រោយយ៉ាងហាក់មកក្របបង្អែះមាណពដាក់ថ្ពាល់នាងប្រមៀលលើ

មុខអ្នកកម្លោះច្រូហោយំរៀបរាប់ :

-បងផានអើយ ! ខ្ញុំមិនដឹងថាបងភ្លេចរឿងចាស់មែនទែនទេ, បងឈឺម្តងនេះធ្ងន់ណាស់មិនទាន់ជាស្រួលបួលឡើយ ។

មាណពផាននារីរូបល្អឱបចង្កេះថ្នាក់ថ្នមកំក្លោះឈឺអស់រលីង ។ នាយដកដង្ហើមយូរបន្ទីរពាថា:

-ទីងៗគុងៗ ! នាងម៉េចអីចឹង ? ម្តងខឹងម្តងសប្បាយ ខ្ញុំមិនយល់ទេ, ហេតុអីហ្នឹង ?

-ហ៊ុ ! ធ្វើម៉េចទៅ ?

នាងស្ទុះក្រោកយកកូនដបមួយពីក្នុងហោប៉ៅចាក់ថ្នាំមួយគ្រាប់តូច ហុចឲ្យមាណពលេបព្រមទាំងពោល :

-ខ្ញុំបន់កុំឲ្យបងមានស្នាមអាក្រក់លើមុខ ។

អ្នកទាំងពីរអស់រឿងនិយាយ ក៏អង្គុយកៀកកើយគ្នាលើកៅអីវែងមួយស្របកល់ ។ បន្ទាប់នោះទីងគុងខ្សឹបដាក់ត្រចៀកមាណពថា:

- បងផានភ្លា ! បងឈឺមួយលើកនេះភ្លេចរឿងចាស់អស់រលីង ហើយភ្លេចយុទ្ធសិល្បៈទៀត ! នៅសល់តែកម្លាំងកាយទេដែលឥតផ្លាស់ប្តូរ ។ ឥឡូវខ្ញុំបង្រៀនស្នៀតចាប់ខ្មាំង ដែលមានប្រយោជន៍បំផុតឲ្យបងចេះណា !

មាណពងក់ក្បាល :

- បើនាងបង្ហាត់បង្ហាញមែន ខ្ញុំយល់ព្រមហើយ ។

ទីងគុងលូកដៃអង្អែលថ្ពាល់មាណពថ្នម ៗ ដោយក្តីករុណា ហើយស្រាប់តែឱនថើបនាយភ្លាម ។ អ្នកកម្លោះភ្ញាក់ព្រើតក្រហមមុខ, ងាកមើលទីងគុងឃើញនាងលើកដៃផ្ទង់សក់បំបាត់ការអៀនខ្មាសដែរ ។ បន្ទាប់ពីនោះទីងគុងចាប់ផ្តើមបង្ហាត់ស្នៀតចាប់ខ្មាំងទាំងដប់ប្រាំបីប្រចាំគ្រួសារទីង ។ លុះពន្យល់ចប់សព្វគ្រប់នាងប្រើមាណពឲ្យធ្វើបង្ហាញខាងមើល ។ សុផានឆ្លាតវាងវៃស្រាប់មើលឃើញចាំស្ទាត់តាមអនុវត្តទ្រឹស្តីបានភ្លាម ។ អ្នកទាំងពីរសាកល្បងគ្នាចំនួនបីថ្ងៃទើបមាណពប្រើស្នៀតទាំងដប់ប្រាំបីស្ទាត់មែនទែន, ឯរបួសក៏ជាសះស្បើយដែរ ។

នៅពេលយុវជនប្រុសស្រីប្រកួតស្នៀតចាប់ខ្មាំងម្តង ៗ ទីងមិនហួសបីអង្គុយមើលធ្វើព្រងើយ, យូរ ៗ គាត់ពោលពាក្យចំអកឲ្យមាណពម្តង ៗ រីឯកូនទូកចេះតែរសាត់តាមទឹកឆ្ងាយទៅ ៗ ..

ថ្ងៃនេះគេមកដល់កន្លែងមួយស្ងាត់ជ្រៀបគ្មានផ្ទះអ្នកស្រុកសោះ ។ ចិនគុនពេញចិត្តនឹង
អ្នកកម្លោះដែលហាត់រៀនឆាប់ចេះគាប់ចិត្តណាស់ ។ ម្ដងនោះនាងឮជីតាជេរមាណពថា ខ្ជិល
ណាទៀត ក៏ឆ្លៀតសួរដើម្បីដាក់កែនគាត់ថា :

-លោកតា ! លោកតា ! យុទ្ធសិល្បៈចាប់ខ្ចាំតាំងដប់បីស្ទៀតប្រចាំគ្រួសារយើង បើបង្រៀន
មនុស្សខ្ជិលណាតើត្រូវហាត់ប៉ុន្មានថ្ងៃ ?

ចិនមិនហួសបីនៅស្ងៀមចាល់ប្រក់ ព្រោះគាត់ឃើញច្បាស់នឹងភ្នែក ថាមាណពហាត់តែបីថ្ងៃក៏
ចេះស្ទាត់គួរសរសើរ ។ ដូច្នេះនាយមិនមែនជាក្មេងខ្ជិលណាទេ ។ គាត់ដណ្ដឹងសួរ :

-អានេះវាធ្វើពើដល់ណាទៀត ? ឬមួយវាក្មេងរៀនចាស់មែន ?

ចិនមិនហួសបីនឿនឆ្ងល់ម្នាក់ឯង តែមិនព្រមបញ្ចេញឲ្យចៅស្រីដឹងទេ ។ គាត់រឹងរូស
ហើយមានះណាស់មិនងាយចុះចាញ់នរណាទេ ។ គាត់ឆ្លើយតបចៅស្រី:

- អើមនុស្សខ្ជិលមានពុនណា , អាខ្លះខ្ជិលឆ្លាត អាខ្លះខ្ជិលល្ងង់ ។ មនុស្សខ្ជិលហើយ
ឆ្លាតរៀនកន្លះថ្ងៃចេះស្ទាត់បើខ្ជិលហើយល្ងង់ដូចបងឯងនេះហាត់បីថ្ងៃបីយប់ទើបចេះចប់ ។

ចិនគុនយកដៃខ្ទប់មាត់សើចហើយសួរទៀត:

-លោកតាក្លៃ ! កាលលោកតាហាត់ស្ទៀតចាប់ខ្ចាំនេះលោកតាចំណាយពេលប៉ុន្មានថ្ងៃ ?

- តាមិនចាំពេលវេលាទេ, គ្រាន់តែដឹងថាឪពុកតានិយាយមួយចប់តាចាំស្ទាត់ចេះប្រើស្ទៀត
តាំងដប់បីភ្លាម ។ បើគិតស្រួលបួលប្រហែលមិនបានកន្លះថ្ងៃផងទេ ។

ចិនគុនសើចទៀត :

- បើអីចឹងលោកតាជាមនុស្សខ្ជិលគុនឆ្លាតទេតើ !

ចិនមិនហួសបីត្រូវចៅស្រីចាប់ចំណុចខ្សោយបានក៏ខឹងក្រេវក្រោធស្រែកគំហក:

- មីចៅចំកួតគ្មានដឹងចាស់ទុំធំតូចសោះតែម្ដង !

ពេលជីតានិងចៅជជែកគ្នានោះមានកូនទូកតូចមួយត្រូវគេអុំលឿនស្ទើរតាមក្រោយ ។ ទូក
នេះមានក្ដោងហើយមានមនុស្សបួននាក់ជួយកុញាប់ដៃ ។ ដោយហេតុទូកស្រាលហើយតូចទើប
មួយផ្លេតក្រោយគេមកជិតដល់ទូកចិនមិនហួសបីហើយឮជនពាក់អាវសពីរនាក់ស្រែកមកពីចម្ងាយ:

-អាល្អិតត្រកូលស៊ីនៅក្នុងទូកខាងមុខហ្នឹងហើយ ។ ឈប់សិន ! ឈប់ ! **(នៅមានត)**

ដំកល់ទុកតាមលេខ . ៣១០ ចុះថ្ងៃទី ២២-៥-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers